# របាយការណ៍
## ស្ដីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១៤
## និងទិសដៅការងារ ខែតុលា ឆ្នាំ២០១៤

(ពីថ្ងៃទី៣១/០៨/២០១៤ ដល់ ៣០/០៩/២០១៤)

ផ្អែកលើផែនការសកម្មភាពអនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី២ ឆ្នាំ២០១៤ និងទិសដៅការងារដែលបានដាក់ចេញកាលពីខែសីហាឆ្នាំ២០១៤កន្លងទៅ ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយភូមិឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ក្នុងខែកញ្ញាឆ្នាំ២០១៤នេះ តាមរយៈរបាយការណ៍ទទួលបានពីអង្គភាពអនុវត្តន៍ច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាល និង កងរាជអាវុធហត្ថ រាជធានី-ខេត្តមួយចំនួន ដែលបានបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរ ជួញដូរ និងប្រើប្រាស់គ្រឿងញៀន បានកើតមាននៅ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, ព្រៃវែង, ស្វាយរៀង, ស្ទឹងត្រែង, រតនគិរី, កំពង់ធំ, បាត់ដំបង, បន្ទាយមានជ័យ, ក្រចេះ, ឧត្តរមានជ័យ និង ខេត្តពោធិ៍សាត់ ។ ក្នុងនោះ ត្រូវបានកត់សំគាល់ឃើញមាន ៣ ករណីធំៗ ដែលបង្ក្រាបដោយមន្ទីរប្រឆាំងគ្រឿងញៀន ១ ករណី និងដកហូត មេតំហ្វេតាមីន ICE ចំនួន ២.៦៥៦,១៤ ក្រាម, បង្ក្រាបដោយកម្លាំងនៃស្នងការដ្ឋាននគរបាលខេត្តរតនគិរី ១ ករណី ដកហូតមេតំហ្វេតាមីន ICE ចំនួន ១.០១៤,៦២ ក្រាម និងបង្ក្រាបដោយកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ១ ករណី ដកហូតមេតំហ្វេតាមីន ICE ចំនួន ៥២៩,១៦ ក្រាម ព្រមទាំងឃាត់ខ្លួនឈ្មួញគ្រឿងញៀនជា ជនជាតិឡាវ ០២ នាក់ និងជនជាតិថៃ ០១ នាក់ ។

## II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### *១. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ ដឹកនាំបញ្ជា

លើការងារជាគោលសំខាន់ៗ ជាអាទិ៍ :

- ជំរុញការរៀបចំកម្មវិធី ប្រឡងគូរគំនូរប្រឆាំងគ្រឿងញៀន នៅខេត្តកោះកុង និងនៅតាមបណ្តាខេត្តគោលដៅមួយចំនួនទៀត ។
- ជំរុញការរៀបចំកែសម្រួលយន្តការគ្រប់គ្រង មណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ សម្រាប់អប់រំ បន្សាបព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- ជំរុញការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាពដែលបានរៀបចំរួច សម្រាប់ការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញ ។
- រៀបចំបង្កើតគណៈកម្មការថ្នាក់ជាតិ ទទួលបន្ទុកកិច្ចការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។
- បើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជំនាញ ដល់មន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិចាប់ពីថ្នាក់ខេត្ត រហូតដល់ថ្នាក់នគរបាលប៉ុស្តិ៍រដ្ឋបាល និងវគ្គបណ្តុះបណ្តាលកងយោធពលខេមរភូមិន្ទនៅតាមបណ្តាភូមិភាគ និងវរយោធាការពារព្រំដែន ។
- ជំរុញការរៀបចំអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន ។
- ជំរុញការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- កែសម្រួលសេចក្តីសម្រេច ស្តីពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ។
- ចូលរួមកែសម្រួលសេចក្តីព្រាងអនុក្រឹត្យ (ថ្មី) ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ (ពាក់ព័ន្ធនឹងអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន) ។

## ២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ២.១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

នៅក្នុងខែកញ្ញានេះ ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែសីហា ឆ្នាំ២០១៤ កន្លងទៅ ក្រសួង-ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន **០៥** គឺ ខេត្តប៉ៃលិន, បាត់ដំបង, កំពង់ចាម, ស្វាយរៀង, ក្រចេះ បានធ្វើសកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន តាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ-សប្តាហ៍-ខែ និងជាពិសេសនៅតាមសហគមន៍ ដែលមានមហាជនចូលរួមប្រមាណ **៦១.១០២** នាក់ លើ **៣៥.០០១** នាក់ [(1)] នៃខែសីហា ឆ្នាំ២០១៤ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១) ។

**ក្នុងនោះ** លទ្ធផលដែលបានអនុវត្តដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមមាន :

- រៀបចំចាត់ចែង សម្របសម្រួលនិងអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្ទឹងត្រែង ដើម្បី

[1] សកម្មភាពផ្សព្វផ្សាយអប់រំ មានការថយចុះដោយសាររដូវវស្សាកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុននានា ត្រូវផ្អាកដំណើរការបណ្តោះអាសន្ន

ផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធី ផ្សាយផ្ទាល់របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០១៤ តាមកម្មវិធី និងប្រធានបទ ដូចខាងក្រោម ៖

១. កម្មវិធីសុវត្ថិភាពអ្នក ក្រោមប្រធានបទ **តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យយុវជនចៀសផុតពីគ្រឿងញៀន**

២. កម្មវិធីចក្ខុវិស័យកម្ពុជា ក្រោមប្រធានបទ **ការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន**

៣. កម្មវិធីសភាអ៊ីនធឺណែត ក្រោមប្រធានបទ **លទ្ធផល និងសកម្មភាពត្រួតពិនិត្យគ្រឿងញៀនក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង**

- បន្តកិច្ចសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកោះកុង រៀបចំកម្មវិធីប្រឡងផ្តាច់ព្រ័ត្រ "ការគូរគំនូរប្រឆាំងគ្រឿងញៀន" ដើម្បីឈានទៅធ្វើការប្រកាសលទ្ធផល និងផ្តល់រង្វាន់ដល់អ្នកដែលជាប់ចំណាត់ថ្នាក់ ។
- ពិភាក្សាការងារជាមួយក្រសួងធម្មការ និងសាសនា ពាក់ព័ន្ធការងារអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ។
- ចូលរួមក្នុងសិក្ខាសាលាសម្របសម្រួលថ្នាក់ក្រោមជាតិ ស្តីពីការជួយគាំទ្រដល់ការអនុវត្តគម្រោងយុត្តិធម៌សហគមន៍នៅកម្ពុជា ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ធ្វើនៅខេត្តសៀមរាប ថ្ងៃទី១១-១៣/៩/២០១៤) ។
- ចូលរួមក្នុងសិក្ខាសាលាស្តីពីផលប៉ះពាល់ នៃការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង ដែលរៀបចំដោយសមាគមយុវជនខ្មែរ (អ្នកចូលរួម ៣៨ នាក់) ។

ជាមួយនេះដែរ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក៏បានបន្តអនុវត្តកម្មវិធីប្រិយមិត្តអ្នកអានគេហទំព័រ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រចាំ**ខែកញ្ញា** ដែលមានប្រិយមិត្តអ្នកអានចំនួន **២៦.៨៦៩** ដង ។

ក្រៅពីការងារខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចាត់បញ្ជូនមន្ត្រីជំនាញ ០៣ រូប ទៅចូលរួមកិច្ចប្រជុំអ្នកសម្របសម្រួលកណ្តាល និងពិគ្រោះយោបល់របស់ក្រុមអ្នកជំនាញផ្នែកអប់រំបង្ការគ្រឿងញៀន នៃ Colombo Plan កាលពីថ្ងៃទី០៣-០៥/៩/២០១៤ នៅខេត្តឈាងម៉ៃ ប្រទេសថៃ ។

## ២.២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

- ***ការកាត់បន្ថយគ្រោះថ្នាក់***

  - ✓ ចូលរួមកិច្ចប្រជុំណែនាំអំពីបណ្តាញមិត្តអប់រំមិត្តអ្នកប្រើប្រាស់គ្រឿងញៀន ទៅកាន់ក្រុមគោលដៅ និងអ្នកពាក់ព័ន្ធ ដែលរៀបចំដោយអង្គការ ខាន់ណា កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ នៅសណ្ឋាគារហ្វ្រីនផាឡេស ។
  - ✓ ចូលរួមកិច្ចប្រជុំពិភាក្សា និងបង្កើតគោលជំហរថ្នាក់ជាតិ សម្រាប់សន្និសីទភាគី លើកទី៦ COP6 នៃក្របខណ្ឌអនុសញ្ញាស្តីពីថ្នាំជក់ ។
  - ✓ ចូលរួមប្រជុំពិភាក្សា ជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីពិនិត្យឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ស្តីពី កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ប្រកបដោយប្រសិទ្ធភាពក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀននៅកម្ពុជា កាលពីថ្ងៃទី១៦-១៧/៩/២០១៤ ។

- ✓ ចូលរួមសិក្ខាសាលាស្តីពី ស្ថានភាពអ្នកប្រើគ្រឿងញៀន និងផែនការយុទ្ធសាស្ត្រទប់ស្កាត់បញ្ហាគ្រឿងញៀន ដែលរៀបចំដោយសមាគមយុវជនខ្មែរ កាលពីថ្ងៃទី១៨/៩/២០១៤ (អ្នកចូលរួម ៣០ រូប) ។

- ***ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន***

ការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បាន ៖

- ✓ ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២១០៤ ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (អ្នកចូលរួម ៣៣ នាក់) ។
- ✓ រៀបចំកិច្ចប្រជុំជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងសុខាភិបាល ដើម្បីបន្តពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការថ្នាក់ជាតិទទួលបន្ទុកកិច្ចការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន កាលពីថ្ងៃទី២៩/៩/២០១៤ ។

## ***២.៣. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់***

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការពង្រឹងប្រសិទ្ធភាពការអនុវត្តច្បាប់ តាមរយៈសកម្មភាពដូចខាងក្រោម ៖

- ✓ បើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់រាជធានីភ្នំពេញ ១២ រូប (វគ្គទី៣ឆ្នាំ២០១៤) ស្តីពីការពង្រឹងសមត្ថភាពក្នុងការត្រួតពិនិត្យគ្រឿងញៀន តាមប្រព័ន្ធកុំព្យូទ័រ (CBT) ពីថ្ងៃទី០១-០៥ខែកញ្ញា ឆ្នាំ២០១៤ ។
- ✓ រៀបចំវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន និង ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់កងយោធពលខេមរភូមិន្ទ នៅយោធភូមិភាគ៣ (ធ្វើនៅខេត្តកំពង់ស្ពឺ ថ្ងៃទី០៩/៩/២០១៤ មានសិក្ខាកាមចូលរួម ៨០ នាក់), យោធភូមិភាគពិសេស (ធ្វើនៅខេត្តកណ្តាល ថ្ងៃទី១១/៩/២០១៤ មានសិក្ខាកាមចូលរួម ១៦០ នាក់) ។

**ដោយឡែក** គ្រូបង្គោលរបស់ក្រសួងការពារជាតិ បានចុះផ្ទាល់ដើម្បីផ្សព្វផ្សាយនូវចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន និង ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់នាយទាហាន នាយទាហានរង និងពលទាហាន នៅយោធភូមិភាគ៣ ចំនួន ៧៤ នាក់ និង យោធភូមិភាគពិសេស ចំនួន ៤៧៧ នាក់ ។

ទន្ទឹមនឹងការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ បានបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀន សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

- បទល្មើសគ្រឿងញៀន សរុប ***១៧០ ករណី*** លើ ១០៧ ករណី នៃខែសីហា ឆ្នាំ២០១៤
- ជនសង្ស័យ ឃាត់ខ្លួន សរុប ***៣៤៥*** នាក់ លើ ២៤៥ នាក់ នៃខែសីហា ឆ្នា២០១៤

  ក្នុងចំនួនបទល្មើសគ្រឿងញៀន ***១៧០ ករណី*** និង ជនសង្ស័យទាំង ***៣៤៥ នាក់*** ខាងលើគឺ :

  - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយសម្ថកិច្ចនគរបាលជាតិ ***១២០ ករណី***, ជនសង្ស័យ ***២១៩***

***នាក់*** (ស្រី ៣២ នាក់)

- ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចកងរាជអាវុធហត្ថ ***៥០ ករណី***, ជនសង្ស័យ ***១២៦ នាក់*** (ស្រី *១៨*នាក់)

- ក្នុងចំនួនជនសង្ស័យ ដែលបានឃាត់ខ្លួនទាំង ៣៤៥ នាក់ ខាងលើ មាន ០៦ សញ្ជាតិ គឺ ខ្មែរ ៣២៨ នាក់ (ស្រី ៣៨ នាក់), វៀតណាម ១១ នាក់ (ស្រី ០៩ នាក់), ឡាវ ០៣ នាក់ (ស្រី ០២), ថៃ ០១ នាក់ (ស្រី), ចិន ០១ នាក់ (ប្រុស), ណ័រវែស ០១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។
- **វត្ថុតាងគ្រឿងញៀនចាប់យក រួមមាន** មេតំហ្វេតាមីន WY ៩៤៣,៣២ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ(ICE) ៥.៤៩៣,៧៧ ក្រាម, កញ្ឆាក្រៀម ០,៦៤ ក្រាម, ប្រេងម្រះព្រៅភ្នំ ១៣៩ ប៊ីដុង, សារធាតុសង្ស័យគ្រឿងញៀន ១.៥៤៣,០៤ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** បានចាប់យករួមមាន ម៉ូតូ ៧៣ គ្រឿង, រថយន្ត ៣ គ្រឿង, ប្រាក់កម្ពុជា ១០.២៤១.៣០០ រៀល, ប្រាក់ថៃ ៥០០ បាត, ប្រាក់អាមេរិក ១៩៥២ ដុល្លារ, **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២ ។**

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៤ ដីកា = មនុស្ស ៤ នាក់ (ប្រុស) ជនជាតិខ្មែរ ។

**ជាមួយនេះ:** មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុងខែកញ្ញា ឆ្នាំ២០១៤ នេះ សរុបចំនួន ៩៥ ករណី = ១១២ សំណាក ។ ក្នុងនោះ **:**

- ✓ **សំណាកវិជ្ជមានសារធាតុញៀន មាន ៩៣ ករណី = ១០៧ សំណាក គឺ** :
  មេតំហ្វេតាមីន ICE ៧០ សំណាក = ៥៧,៣៧ %,
  មេតំហ្វេតាមីន WY ៣៣ សំណាក = ២៧,០៤ %
  កេតាមីន = ០៩ សំណាក = ៧,៣៧ %, ហេរ៉ូអ៊ីន ០១ សំណាក = ០,៨១ %
  MDMA = ០៣ សំណាក = ២,៤៥ %, នីមេតាហ្សេប៉ាម ០១ សំណាក = ០,៨១ %
- ✓ **សំណាកអវិជ្ជមានសារធាតុញៀន ០២ ករណី = ០៥ សំណាក** = ០,០៩ %

## *២.៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុងខែកញ្ញាឆ្នាំ២០១៤នេះ មានដូចតទៅ ៖

- សារធាតុគីមីចម្រុះ ដែលពាក់ព័ន្ធនឹងតារាង ទីIV នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន សរុបចំនួន ***៦៥២.៥១៤*** គ.ក្រ ***៨.០៤៦*** លីត្រ និង ***៦០*** អំពូល ក្នុងនោះ ៖
  - ✓ សារធាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ៣៩៩.០១៤ គ.ក្រ ៨.០៤៦ លីត្រ និង ៦០ អំពូល
  - ✓ សារធាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ២៥៣.៥០០ គ.ក្រ
- វត្ថុធាតុដើមប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលចេញអាជ្ញាបណ្ណដោយក្រសួងសុខាភិបាល និងពាក់ព័ន្ធ

ជាមួយ តារាង II, តារាងIII នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ១០០ ^គ.ក្រ^

- ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលនាំចូលដោយក្រសួងសុខាភិបាល និងពាក់ព័ន្ធជាមួយ តារាង II, តារាងIII នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន ០១ ^គ.ក្រ^ ១១៧៩ ^ក្រាម^ ៥៣០ ^មីលីក្រាម^

**ជាមួយនេះ អគ្គលេខាធិការដ្ឋាន** បាន ៖

- បន្តការរៀបចំបែបបទប្រគល់ ប្រេងម្រះព្រៅភ្នំ ចំនួន ១.៧០០ ^លីត្រ^ និង ១២៣ ^គ.ក្រ^ ទៅក្រសួងឧស្សាហ-កម្ម និងសិប្បកម្ម ដើម្បីបន្តការគ្រប់គ្រង និងចាត់ចែងតាមសមត្ថកិច្ច ។
- បានចាត់មន្ត្រីជំនាញចុះសិក្សាស្រាវជ្រាវករណីប្រេងម្រះព្រៅភ្នំ ដែលសមត្ថកិច្ចខេត្តពោធិ៍សាត់រកឃើញ និងចាប់យកចំនួន ១៣៩ ប៊ីដុង កាលពីថ្ងៃទី១៧, ១៨ និង ២៦ ខែសីហា ឆ្នាំ២០១៤ ។
- រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជិតខាង

- បានចូលរួមកិច្ចប្រជុំត្រៀមសម្រាប់កិច្ចប្រជុំគណៈកម្មាធិការចម្រុះអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម លើកទី៩ និងកិច្ចប្រជុំពាក់ព័ន្ធ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ។
- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម លើកទី៩ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី០៨-១២ខែកញ្ញា ឆ្នាំ ២០១៤ នៅទីក្រុងសៀមរាប ។

**ដោយឡែក** ខេត្តបាត់ដំបង បានចាត់បញ្ជូនមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) ប្រកដួង និងមន្ត្រីពាក់ព័ន្ធ ២០ រូប ទៅចូលរួមប្រជុំផ្លាស់ប្តូរព័ត៌មាន និងពិភាក្សាលើគម្រោងបណ្តុះបណ្តាលមន្ត្រីការិយាល័យ (BLO) កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ នៅការិយាល័យទំនាក់ទំនងព្រំដែន ស្រុកប៉ុងណាំរ៉ន ខេត្តចន្ទបុរី ប្រទេសថៃ ។

## ២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ

- បានសម្របសម្រួលជាមួយការិយាល័យត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) និង Colombo Plan ដើម្បី ចាត់បញ្ជូនមន្ត្រីទៅចូលរួមកិច្ចប្រជុំក្រុមមន្ត្រីសម្របសម្រួលថ្នាក់កណ្តាល និងពិគ្រោះយោបល់របស់ក្រុមអ្នកជំនាញផ្នែកអប់រំបង្ការគ្រឿងញៀន កាលពីថ្ងៃទី០៣-០៥ ខែកញ្ញា ឆ្នាំ២០១៤ នៅខេត្តឈាងម៉ៃ ប្រទេសថៃ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប, មន្ត្រីសុខាភិបាល ០១ រូប) ។
- បានសម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចូលរួមសន្និបាតអនុវត្តន៍ច្បាប់អនុតំបន់ទន្លេ មេគង្គ (GMSDEC) ឆ្នាំ២០១៤ កាលពីថ្ងៃទី២៤-២៥/៩/២០១៤ នៅទីក្រុងប៉េកាំង ប្រទេសចិន (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប) ។
- បានសម្របសម្រួលជាមួយស្ថាប័ន GIZ និង TNI ដើម្បីបញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប ទៅចូលរួមក្នុងកិច្ចប្រជុំ GIZ/INI ស្តីពីការសន្ទនាក្រៅផ្លូវការអំពីគោលនយោបាយគ្រឿងញៀនអាស៊ាន កាលពីថ្ងៃទី២៩-៣០/៩/២០១៤ នៅទីក្រុងដេលី ប្រទេសឥណ្ឌា ។
- បានសម្របសម្រួលជាមួយអង្គការ JICA ដើម្បីចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប ទៅទទួលវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន ពីថ្ងៃទី៣១ ខែសីហា ដល់ថ្ងៃទី

១៣ ខែកញ្ញា ឆ្នាំ២០១៤ នៅប្រទេសជប៉ុន ។

- បានសម្របសម្រួលជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានចូលរួមកិច្ចប្រជុំ ASEAN-NARCO ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃ ទី១៤-១៨/៩/២០១៤ នៅទីក្រុងបាងកក និង ខេត្តស៊ូរ៉ាតថានី ប្រទេសថៃ ។

### ២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹងនិងពង្រីកលទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យឲ្យមានប្រសិទ្ធភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- បន្តការកែសម្រួលអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ចូលរួមកែសម្រួលសេចក្តីព្រាងអនុក្រឹត្យ (ថ្មី) ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ (ពាក់ព័ន្ធនឹងអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន) ។
- ពិនិត្យ កែសម្រួល លើសេចក្តីព្រាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ។
- បន្តរៀបចំអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន ។
- រៀបចំប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន ។
- រៀបចំបង្កើតគណៈកម្មាធិការថ្នាក់ជាតិ ទទួលបន្ទុកកិច្ចការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។
- ចូលរួមក្នុងកិច្ចប្រជុំ រៀបចំផែនការត្រួតពិនិត្យគ្រឿងញៀន របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានីភ្នំពេញ (១៦/៩/២០១៤ អ្នកពាក់ព័ន្ធចូលរួម ៣០៦ នាក់) ។
- កែសម្រួលសេចក្តីសម្រេចស្តីពី ការកែសម្រួល សមាសភាព តួនាទី និងភារកិច្ច របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែតុលា ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តសម្របសម្រួល ជំរុញអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### *១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ និងបដិសេធគ្រឿងញៀន*

**១.១.** រៀបចំចាត់ចែង សម្របសម្រួល និងអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកំពង់ចាម ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ស្តីពីសកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀននៅក្នុងភូមិសាស្ត្រ របស់ខេត្តកំពង់ចាម (ថ្ងៃទី២២/១០/២០១៤) ។

**១.២.** ចូលរួមក្នុងសិក្ខាសាលាស្តីពី ការបញ្ជ្រាបវិធានការ និងហានិភ័យក្នុងការសេពគ្រឿងញៀន នៅថ្ងៃទី

០៣/១០/២០១៤ និងពិធីបើកមហោស្រព តន្ត្រី និងចម្រៀងកុមារ ពានរង្វាន់ក្រសួងព័ត៌មាន ឆ្នាំ ២០១៤ នៅថ្ងៃទី០៤/១០/២០១៤ ដែលរៀបចំដោយក្រសួងព័ត៌មាន ។

***១.៣.*** ចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ០១រូប ទៅចូលរួមកិច្ចប្រជុំភាពជាដៃគូតំបន់អាស៊ីអាគ្នេយ៍ IIW ឆ្នាំ២០១៤ ដែលរៀបចំដោយស្ថាប័នអន្តរជាតិនៃ IOGT-NTO MOVEMENT ការិយាល័យតំបន់អាស៊ីអាគ្នេយ៍ នៅទីក្រុងបាងកក នាថ្ងៃទី២៧ ខែតុលា ដល់ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

***១.៤.*** ត្រៀមសហការជាមួយក្រុមហ៊ុន Musashi Advertising Co., LTD ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅរាជធានីភ្នំពេញ តាមរយៈការបញ្ចាំងរូបភាព និងភាពយន្តខ្លី នៅលើរថយន្តចល័ត ។

***១.៥.*** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន និងការបង្ការទប់ស្កាត់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផលស៊ីហ្សា និង បារីអេឡិចត្រូនិច នៅតាមរាជធានី-ខេត្តទូទាំងប្រទេស ។

***១.៦.*** សហការជាមួយក្រសួងទេសចរណ៍ ដើម្បីរៀបចំផលិតបន្ថែមនូវស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន អេដស៍ ការប្រើប្រាស់អាវុធ និងការជួញដូរមនុស្ស ។

***១.៧.*** បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករតន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ។

***១.៨.*** បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និងនៅតាមសហគមន៍ ។

***១.៩.*** បន្តការជួបពិភាក្សាការងារជាមួយក្រសួងធម្មការ និងសាសនា លើការងារអប់រំផ្សព្វផ្សាយ ។

***១.១០.*** សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តគោលដៅ និងវិស័យឯកជន ដើម្បីបន្តរៀបចំកម្មវិធីប្រគំតន្ត្រីអប់រំពីបញ្ហាគ្រឿងញៀន ។

## ***២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន***

***២.១.*** សហការជាមួយក្រសួងសុខាភិបាល និងអង្គការ FHI360 រៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការសិក្សាស្រាវជ្រាវ ពីការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ និងគ្រឿងញៀន នៅកម្ពុជា ថ្ងៃទី០២/១០/២០១៤។

***២.២.*** សហការជាមួយអង្គការ FHI360 រៀបចំសិក្ខាសាលាផ្សព្វ ផ្សាយឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ និងអាជ្ញាធរមូលដ្ឋាន ក្នុងការចូលរួមអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀន ។

***២.៣.*** ត្រៀមចូលរួមកិច្ចប្រជុំអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាលើប្រធានបទស្តីពី បច្ចុប្បន្នភាព នៃការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង ដែលរៀបចំដោយមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព នៅថ្ងៃទី៣០/៩/២០១៤ ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន ។

***២.៤.*** បន្តជំរុញក្រសួងសុខាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញក្នុងការបង្កើត

សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

***២.៥.*** បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

***២.៦.*** បន្តការរៀបចំបង្កើតគណៈកម្មាធិការថ្នាក់ជាតិទទួលបន្ទុកកិច្ចការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

## ៣. *ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់*

***៣.១.*** បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទ យោធភូមិភាគ២ និង យោធភូមិភាគ១ ។

***៣.២.*** បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ (វគ្គទី៤ ឆ្នាំ២០១៤) ដល់មន្ត្រីអនុវត្តន៍ច្បាប់រាជធានីភ្នំពេញ ចំនួន ១២ រូប (ថ្ងៃទី០៦-១០/១០/២០១៤ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ) ។

***៣.៣.*** ត្រៀមទទួលប្រតិភូគ្រឿងញៀនឥណ្ឌូនេស៊ី និងទីម័រខាងកើត មកធ្វើទស្សនកិច្ចសិក្សានៅការិយាល័យទំនាក់ទំនងព្រំដែន (BLO) ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១០/១០/២០១៤ ។

***៣.៤.*** ត្រៀមរៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់ តាមច្រកអាកាសយានដ្ឋានអន្តរជាតិ ។

***៣.៥.*** ត្រៀមធ្វើបទបង្ហាញដល់សមត្ថកិច្ចកងរាជអាវុធហត្ថ ក្នុងវគ្គបំប៉នការងារស្រាវជ្រាវប្រឆាំងបទល្មើសគ្រឿងញៀន នៅថ្ងៃទី១៣-១៧/១០/២០១៤ ។

## ៤. *ការត្រួតពិនិត្យសារធាតុគីមីផ្សំ*

***៤.១.*** រៀបចំឯកសារសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។

***៤.២.*** បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

***៤.៣.*** សិក្សាស្រាវជ្រាវនិងប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុថ្មី ដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

***៤.៤.*** បន្តជំរុញនីតិវិធីក្នុងការប្រគល់និងទទួលប្រេងម្រះព្រៅភ្នំ ចំនួន ១.៧០០ លីត្រ និង ១២៣ គ.ក្រ ទៅឲ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ព្រមទាំងសហការជាមួយខេត្តពោធិ៍សាត់ ស្រាវជ្រាវករណីប្រេងម្រះព្រៅភ្នំចំនួន ១៣៩ ប៊ីដុង ដែលសមត្ថកិច្ចខេត្តពោធិ៍សាត់រកឃើញកាលពីថ្ងៃទី១៧, ១៨ និងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ។

***៤.៥.*** រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

***៤.៦.*** ត្រៀមរៀបចំកិច្ចប្រជុំជាមួយ ក្រសួងសុខាភិបាល, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីពិភាក្សាលើការប្រមូលទិន្នន័យនាំចូល ការប្រើប្រាស់ និងសន្និធិសារធាតុគីមីផ្សំ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង

**៥.១.** សម្របសម្រួលជាមួយប្រទេសជិតខាង ក្នុងការជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ / កម្ពុជា-វៀតណាម / កម្ពុជា-ឡាវ ។

**៥.២.** សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន ប្រទេសវៀតណាម និងប្រទេសឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសឡាវ និងប្រទេសវៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ

**៦.១.** សម្របសម្រួលជាមួយអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ដើម្បីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំ APICC និង ADLOMICO នៅសាធារណរដ្ឋកូរ៉េ ដែលនឹងប្រព្រឹត្តទៅថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ។

**៦.២.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចូលរួមក្នុងកិច្ចប្រជុំប្រមុខនៃស្ថាប័នជាតិអនុវត្តច្បាប់គ្រឿងញៀន (HONLEA) លើកទី៣៨ ពីថ្ងៃទី២១-២៤/១០/២០១៤ នៅប្រទេសថៃ ។

**៦.៣.** សម្របសម្រួលជាមួយអង្គការ IOGT-NTO MOVEMENT ប្រចាំតំបន់ ដើម្បីចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ០១ រូប ទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ នៃដៃគូអនុវត្តគម្រោងស្តីពី ការអប់រំបង្ការការប្រើបំពានគ្រឿងញៀន គ្រឿងស្រវឹង និងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៧ ខែតុលា ដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅទីក្រុងឈាងម៉ៃ ប្រទេសថៃ ។

**៦.៤.** សម្របសម្រួលជូនតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ និងតំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីចូលរួមសិក្ខាសាលាស្តីពីការបង្កើនសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងសន្និបាតស្តីពីការគាំទ្ររួមបញ្ចូលគ្នានៃអាស៊ីអាគ្នេយ៍ ដើម្បីប្រសិទ្ធភាពសន្តិសុខសាធារណៈ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០-៣១/១០/២០១៤ នៅសាលសន្និសីទអង្គការសហប្រជាជាតិ នាទីក្រុងបាងកក ប្រទេសថៃ ។

**៦.៥.** ត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន លើកទី៥ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដែលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនេះ ចាប់ពីថ្ងៃទី៣០ ខែតុលា ដល់ ០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅខេត្តព្រះសីហនុ ។

**៦.៦.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់កម្មវិធីបណ្តុះបណ្តាលចល័តស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ។

**៦.៧.** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ពីគម្រោង PATROL របស់អង្គការ UNODC ។

**៦.៨.** សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន ដើម្បីត្រៀមដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

## ៧. *ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*

**៧.១.** បន្តការកែសម្រួលអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**៧.២.** ចូលរួមកែសម្រួលសេចក្តីព្រាងអនុក្រឹត្យ (ថ្មី) ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ (ពាក់ព័ន្ធនឹងអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន) ។

**៧.៣.** បន្តការពិនិត្យ កែសម្រួល លើសេចក្តីព្រាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ។

**៧.៤.** ជំរុញការរៀបចំអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន ។

**៧.៥.** ជំរុញការរៀបចំប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយនិងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន ។

**៧.៦.** បន្តការរៀបចំបង្កើតគណៈកម្មាធិការថ្នាក់ជាតិ ទទួលបន្ទុកកិច្ចការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

**៧.៧.** ចូលរួមធ្វើបទឧទ្ទេសនាមស្តីពី តួនាទី ភារកិច្ច រចនាសម្ព័ន្ធ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងយុទ្ធសាស្ត្រក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន (ថ្ងៃទី០៣/១០/២០១៤ សិក្ខាកាមជាកងរាជអាវុធហត្ថ ចំនួន ៦៦ រូប) ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ

"ដើម្បីជូនជ្រាប"

- ក្រសួង សមាជិក អ.ជ.ប.គ.ញ
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

- ឯកសារ